**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ០៦ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតគណៈកម្មការសម្រាប់កំណត់សមត្ថកិច្ចគ្រប់គ្រង និងការប្រើប្រាស់ប្រេកង់ស៍៧០០ MHz

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

## សម្រេច

**ប្រការ១ ..**

ត្រូវបានបង្កើតគណៈកម្មការដើម្បីសិក្សាស្តីពីស្ថានភាពបច្ចុប្បន្ននៃការគ្រប់គ្រង ការបែងចែក និងការប្រើប្រាស់ប្រេកង់ស៍៧០០ MHz សម្រាប់កំណត់សមត្ថកិច្ចគ្រប់គ្រង និងការប្រើប្រាស់ប្រេកង់ស៍៧០០ MHz ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តម **ត្រាំ អ៊ីវតឹក** | រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ប្រធាន |
| ២-ឯកឧត្តម **សារ៉ាត់ ខាន់** | រដ្ឋលេខាធិការប្រចាំការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ៣-ឯកឧត្តម **សុខ ពុទ្ធិវុធ** | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ៤-ឯកឧត្តម **ជា មានិត** | រដ្ឋលេខាធិការ និងជានាយកខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |

| | | |
|---|---|---|
| ៥-ឯកឧត្តម **សុខ ប្រសិទ្ធ** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ៦- ឯកឧត្តម **ម៉ុម ចរិយា** | ប្រធាននិយ័តករទូរគមនាគមន៍កម្ពុជា | សមាជិក |
| ៧- ឯកឧត្តម **អៀង ស៊ុនលី** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៨- ឯកឧត្តម **ញឹក កោសល្យវិជ្ជា** | សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នៃទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៩- ឯកឧត្តម **លឹម ឧុត្តី** | អគ្គនាយកនៃអគ្គនាយកដ្ឋានគ្រប់គ្រងធនធានវិសាលគមន៍ ហ្រ្វេកង់ស៍វិទ្យុ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក។ |

**ប្រការ២ .-**

គណៈកម្មការនេះមានតួនាទីនិងភារកិច្ចសំខាន់ៗដូចខាងក្រោម៖

- ដឹកនាំនិងសម្របសម្រួលលើការងាររៀបចំការសិក្សាស្ដីពីស្ថានភាពបច្ចុប្បន្ននៃការគ្រប់គ្រង ការបែងចែក និងការប្រើប្រាស់ហ្រ្វេកង់ស៍៧០០ MHz ឱ្យទទួលបានជោគជ័យ
- ប្រមូលធាតុចូលទាំងអស់ពាក់ព័ន្ធនឹងការបែងចែក និងការប្រើប្រាស់ហ្រ្វេកង់ស៍៧០០ MHz ពីក្រសួង ស្ថាប័នពាក់ព័ន្ធនានា
- ដឹកនាំរៀបចំសិក្ខាសាលាថ្នាក់ជាតិ ដោយសហការជាមួយនឹងសហភាពទូរគមនាគមន៍អន្តរជាតិ ដៃគូសន្ទនានិងដៃគូអភិវឌ្ឍពាក់ព័ន្ធ ព្រមទាំងវិស័យឯកជន ដើម្បីធានាអនុលោមភាពរបស់កម្ពុជាជាមួយនឹងសុខដុមនីយកម្មតំបន់និងពិភពលោក លើសមត្ថកិច្ចគ្រប់គ្រង និងការប្រើប្រាស់ហ្រ្វេកង់ស៍៧០០ MHz និងដើម្បីទទួលបាននូវការចូលរួមចែករំលែកអំពីឧត្តមានុវត្តន៍លើសមត្ថកិច្ចគ្រប់គ្រង និងការប្រើប្រាស់ហ្រ្វេកង់ស៍៧០០ MHz នៅក្នុងតំបន់ និងពិភពលោក
- ដឹកនាំរៀបចំនិងកំណត់សមត្ថកិច្ចគ្រប់គ្រងនិងការប្រើប្រាស់ហ្រ្វេកង់ស៍៧០០ MHz
- គណៈកម្មការអាចសហការឬស្នើឱ្យមានកិច្ចសហការពីក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍតាមតម្រូវការជាក់ស្តែង
- រៀបចំនិងដាក់ជូនលទ្ធផលស្តីពីការសិក្សានិងការកំណត់សមត្ថកិច្ចនិងការប្រើប្រាស់ហ្រ្វេកង់ស៍៧០០ MHz ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច។ សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលើកិច្ចការនេះនឹងត្រូវបានប្រើប្រាស់ដើម្បីធ្វើជាមូលដ្ឋានបន្ថែមនៃការរៀបចំសេចក្តីព្រាងច្បាប់គមនាគមន៍វិទ្យុ។

**ប្រការ៣ .-**

គណៈកម្មការនេះ មានសិទ្ធិអញ្ជើញមន្ត្រីជំនាញជាតិនិងអន្តរជាតិ មកចូលរួមផ្តល់យោបល់បន្ថែមលើប្រធានបទនេះ ហើយអាចចាត់តាំងក្រុមការងារតាមការចាំបាច់។

**ប្រការ៤ .-**

គណៈកម្មការនេះមានសិទ្ធិប្រើត្រារបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

**ប្រការ៥ .-**

សេចក្តីសម្រេចលេខ១៧ សសរ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មការសម្រាប់កំណត់សមត្ថកិច្ចគ្រប់គ្រងនិងការប្រើប្រាស់ហ្រ្វេកង់ស៍៧០០ MHz និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ៥ កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមករា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ